# ប្រពៃណីទំនៀមទម្លាប់ដក់ជាប់លើគំនូរ (ភាគ២បញ្ចប់)

នៅក្នុងអត្ថបទភាគ១ ខ្ញុំបានរៀបរាប់អំពីទំនៀមទម្លាប់ ដែលសង្កេតឃើញមានគូរជាប់លើគំនូរនៅតាមវត្ត ហើយបន្តប្រតិបត្តិរហូតដល់សព្វថ្ងៃដូចជា ទំនៀមព្រះរាជពិធីច្រត់ព្រះនង្គ័ល និងទំនៀមអាពាហ៍ពិពាហ៍ ឬមង្គលការ។ នៅក្នុងអត្ថបទបញ្ចប់ភាគ២នេះ ខ្ញុំសូមរៀបរាប់យ៉ាងសង្ខេបនូវសិល្បៈទំនៀមទម្លាប់មួយចំនួនទៀត ដែលវិចិត្រករបានគូរបញ្ចូលទៅក្នុងទិដ្ឋភាពខ្លះនៃគំនូរតាមវត្តដូចជា ពិធីក្នុងទំនៀមទម្លាប់ខ្មែរ និងសិល្បៈក្មេងប្រពៃណីផ្សេងៗដូចខាងក្រោម។

### គ.ពិធីកោរជុក

កោរជុក ជាពិធីដែលអ្នកស្រាវជ្រាវយល់ថា គឺជាផ្នែកមួយនៃដំណាក់កាលឆ្លងវ័យរបស់មនុស្សខ្មែរ។[1] ពាក្យថា "ជុក" នេះគឺនិយាយតាមពាក្យថាជាទូទៅ ឯអ្នកស្រុកនៅតំបន់ខាងជើង និងពាយព្យនៃប្រទេសកម្ពុជាច្រើនហៅថា "កំប៉ោយ" ឬ "កំប៉ោច" ហើយបើគេចង់និយាយពីកិច្ចពិធីកាត់កំប៉ោចជាស្ថាពរនោះ គេច្រើននិយាយសាមញ្ញថា "កោរសក់"។[2] បច្ចុប្បន្ន គេឃើញទំនៀមនេះបន្តប្រារព្ធតាមភូមិមួយចំនួននៅតំបន់អង្គរ។ ប៉ុន្តែកាលដើមសតវត្សទី២០ គេដឹងថាមានបុណ្យកោរជុកដ៏អធិកអមមួយបានប្រារព្ធថ្វាយ **ព្រះអង្គម្ចាស់ចន្ទលេខា** (ហៅម្ចាស់តូ) ដែលត្រូវជាព្រះរាជបុត្ររបស់ **ព្រះបាទ នរោត្តម** ដែរ។[3] ពាក់ព័ន្ធពិធីខាងលើ គេឃើញមាននៅក្នុងគំនូររឿងរាមកេរ្តិ៍ គូរនៅលើជញ្ជាំងព្រះវិហារវត្តរាជបូព៌ ខេត្តសៀមរាប។ ក្នុងគំនូរនោះមានរូបពាលីពរអង្គទទៅឱ្យតាបសប្ញសីកោរជុក (រូបលេខ១-២) ហើយបើប្រៀបមកសព្វថ្ងៃ គឺឃើញដូចតួអង្គព្រះសង្ឃឧបកិច្ចធ្វើជាកោរឱ្យក្មេងៗជាសាមីពិធី (រូបលេខ៣-៤)។ ប្រការនេះពុំប្លែកអ្វីឡើយ ដ្បិតត្រូវយល់ថាពុទ្ធបរិស័ទតែងភ្ជាប់កិច្ចជាច្រើនក្នុងទំនៀមប្រពៃណី ទៅនឹងព្រះសង្ឃព្រះពុទ្ធសាសនាជាធម្មតាក្នុងនាមជាពុទ្ធសាសនិក។

---

[1] អាំង ជូលាន, ២០០៥-២០០៦, ទំ. ៤១-៤២

[2] ខៀវ ច័ន្ទ និង អ៊ឹម សុខរិទ្ធី "កោរជុកនៅអង្គរវត្ត" ផ្សាយលើតំណ https://www.yosothor.org/publications/khmer-renaissance/chapter-two/kor-chuk-nov-angkor.html

[3] សូមអាន៖ *Cambodge; Les Fêtes Civiles, Religieuses Bouddhiques Privées, de Famille et Propitiatoires*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២១-២ គំនូរបង្ហាញពិធីកោរសក់ស្វាអង្គទ ដែលគូរនៅវត្តរាជបូព៌ ខេត្តសៀមរាប



រូបលេខ២៣-២ អ្នកស្រុកនៅភូមិត្នោតជ្រុំ ក្នុងស្រុកពួក ខេត្តសៀមរាប ប្រារព្ធពិធីកោរជុក (ឆ្នាំ២០១៩)

## ឃ.ពិធីបំបួសនាគ

តាមព្រះពុទ្ធសាសនាគេជឿថា "បួស" ឬ "បំបួស" បានអានិសង្សបុណ្យដ៏ប្រសើរតទៅជាតិមុខ ហើយក្នុងបរិបទវប្បធម៌ខ្មែរ អ្នកស្រាវជ្រាវក៏ចាត់ទុកការបួសជាផ្នែកមួយនៃទំនៀមក្នុងដំណើរឆ្លងវ័យរបស់មនុស្សដែរ។ ជារឿយៗព្រះសង្ឃតែងតែទេសនាបង្ហាញប្រវត្តិពាក់ព័ន្ធនឹងការបួសដូចជា រឿងយសកុលបុត្រ ដូចគំនូរវត្តស្វាយសាច់ភ្នំ(រូបលេខ៥) និងរឿងសុបិនកុមារ ដែលតែងឃើញគូរតាមព្រះវិហារ និងសាលាឆាន់ជាដើម។ ចំពោះការបួសក្នុងសង្គមខ្មែរមានច្រើនយ៉ាងដូចជា បួសមុខភ្លើង បួសលាបំណន់ បួសសងគុណ និងបួសរៀនវែងឆ្ងាយតាមផ្លូវសាសនាជាដើម។ បុរសដែលរបានបួសរៀនច្រើនវស្សា លុះចាកសិក្ខាបទវិញបុរាណលោកឱ្យតម្លៃថាអ្នកនោះបានរៀនចេះដឹងច្រើន និងមានចរិយា

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

មារយាទល្អផង។ ទំនៀមបួសក្នុងសំណាក់ព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ ក៏មានប្រារព្ធជាប្រក្រតីក្នុងព្រះបរមរាជវាំង។ តាមឯកសារព្រះរាជពិធីទ្វាទសមាស ព្រះរាជពិធីនេះតែងប្រារព្ធនៅថ្ងៃ១៤-១៥ កើតខែអាសាឍ ហៅថា "បួសនាគហ្លួង"។[4] ចំណែករាស្ត្រសាមញ្ញជនម្នា ច្រើនកំណត់ថ្ងៃបួសជាទំនៀមមកក្នុងវេលាពិសាខបូជា ឬចូលព្រះវស្សា ដោយជាប់នូវជំនឿអានិសង្សដូចរៀបរាប់ខាងលើ (រូបលេខ២៦)។



រូបលេខ២៥ គំនូរព្រះសម្មាសម្ពុទ្ធទ្រង់បំបួសយសកុលបុត្រ (វត្តស្វាយសាច់ភ្នំ)



រូបលេខ២៦ ពិធីបំបួសនាគ ដែលប្រារព្ធតាមទំនៀមទម្លាប់របស់អ្នកស្រុក

## ង.វង់ភ្លេងពិណពាទ្យ និងសិល្បៈតែយ៉ាំ

ក្រៅអំពីពិធីជាទំនៀមប្រពៃណីដែលប្រារព្ធប្រតិបត្តិក្នុងសង្គម ហើយជាប់ពាក់ព័ន្ធនឹងគំនូរដូចរៀបរាប់ខាងលើ គេឃើញអន្ទើខ្លះនៅក្នុងរឿងពុទ្ធប្រវត្តិ ឬរឿងជាតកក៏មានគូរបញ្ចូលវង់ភ្លេងសិល្បៈខ្មែរ ជាពិសេសគឺវង់ភ្លេងពិណពាទ្យ និងតែយ៉ាំ។ គំនូរនៅព្រះវិហារវត្តកំពង់ត្រឡាចលើ ខេត្តកំពង់ឆ្នាំង ដើមសតវត្សរ៍ទី២០ គេគូរបង្ហាញវង់ភ្លេងពិណពាទ្យវង់ធំ ប្រគំក្នុងព្រះរាជពិធីអភិសេកព្រះសិទ្ធត្ថ និងព្រះនាងពិម្ពា។ ឧបករណ៍ភ្លេងមានដូចជា គងវង់តូច១ គងវង់ធំ១ រនាតឯក១ រនាតធុង១ រនាតដែក១ ស្គរធំ១គូ ស្រឡៃ១ សម្ភោរ១ និងឈិង១គូ (រូបលេខ២៧)។ ចំណែកឯគំនូរនៅវត្តព្រះធាតុបាស្រី ស្ថិតក្នុងខេត្តត្បូងឃ្មុំ គូរក្នុងរវាងទសវត្សរ៍ទី៥០ ក៏មានបង្ហាញឧបករណ៍ភ្លេងស្រដៀងគំនូរវត្តកំពង់ត្រឡាចលើ ហើយថែមទាំងសរសេរបញ្ជាក់ថាជា "ភ្លេងព្រះរាជទ្រព្យ" ផង (រូបលេខ២៨)។

4 ចាប ពិន ១៩៦០: ២៥-៣៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បច្ចុប្បន្នវង់ភ្លេងនេះប្រើឧបករណ៍ភ្លេងស្ទើរដូចនឹងគំនូរដែរ ហើយជាទូទៅប្រគំកំដររបាំបុរាណ របាំប្រពៃណី ល្ខោនខោល ល្ខោនស្បែក និងពិធីបុណ្យបែបសាសនាទាំងសម្រាប់ព្រះមហាក្សត្រ និងប្រជារាស្ត្រ។[5]

ចំណែកឯសិល្បៈឆៃយ៉ាំ ដែលគេសម្គាល់ឃើញគូរនៅលើគំនូរតាមវត្ត ភាគច្រើនគូរបញ្ចូលក្នុងរឿងព្រះនរជីវកឋិនជាតក និងនៅត្រង់រឿងនាងវិសាខាមានចិត្តសទ្ធាដង្ហែកឋិនដូចជានៅព្រះវិហារវត្តព្រែកបង្កង(រូបលេខ៩) និងគូរនៅព្រះវិហារវត្តសុវណ្ណសាគរស្ថិតក្នុងខេត្តកណ្តាលជាដើម (រូបលេខ១០)។ ក្នុងវប្បធម៌ខ្មែរ សិល្បៈនេះមានប្រជាប្រិយណាស់ ជាពិសេសគឺតែងដង្ហែពិធីតូចធំផ្សេងៗឱ្យមានភាពសប្បាយរីករាយដូចជា កឋិន បុណ្យផ្កា បំបួសនាគ ហែក្បួន និងទទួលស្វាគមន៍ភ្ញៀវ ។ល។ សិល្បករច្រើនតែគូរមុខឬពាក់មុខត្លុកកំប្លុកកំប្លែងដូចឃើញក្នុងគំនូរតាមវត្តទាំងនោះស្រាប់ (រូបលេខ១១)។



រូបលេខ៧ គំនូរវង់ភ្លេងពិណពាទ្យ គូរនៅព្រះវិហារវត្តកំពង់ត្រឡាចលើ



រូបលេខ៨ គំនូរវង់ភ្លេងព្រះរាជទ្រព្យគូរនៅវត្តព្រះធាតុបាស្រី ខេត្តត្បូងឃ្មុំ



រូបលេខ៩ គំនូរឆៃយ៉ាំ គូរនៅវត្តព្រែកបង្កង



រូបលេខ១០ គំនូរឆៃយ៉ាំ គូរនៅវត្តសុវណ្ណសាគរ



រូបលេខ១១ សិល្បៈឆៃយ៉ាំ ដង្ហែអង្គកឋិនទានសព្វថ្ងៃ

[5] ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ២០១៧, ទំ.៣៦-៣៧

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

### ច.ល្បែងរបាំផ្សេងទៀត

ដោយឡែកចំពោះល្បែងរបាំផ្សេងទៀត ដែលតែងឃើញគូរភ្ជាប់នឹងគំនូរតាមវត្តគឺច្រើនតែស្ថិតក្នុងសកម្មភាពសម្ដែងកំដរពិធីផ្សេងៗ ជាពិសេសគឺក្នុងពិធីរាជាភិសេកដូចវង់ភ្លេងពិណពាទ្យដែរ ហើយមានដូចជាល្បែងចំបាប់ និងសិល្បៈប្រើរាងកាយ (ឬហៅតាមនិយមថា"សៀក" ឬ"ប៉ាហ៊ី")[6] គំនូរក្នុងព្រះវិហារវត្តកំពង់ត្រឡាចលើដដែលនោះ បង្ហាញឱ្យឃើញមានល្បែងផ្សេងៗដូចជា យោលទោង សួព្រ័ត្រ គុនដំបង (ឬលំពែង) និងការបង្ហាញទេពកោសល្យពត់ខ្លួន ដេកលើដែកគោល ឬដាំក្បាលចុះក្រោមនៅលើបង្គោលខ្ពស់ និងទម្លាក់ខ្លួនតាមប្រឡោះកងជាដើម (រូបលេខ១២)។ គួរកត់សម្គាល់ថា គំនូរដែលមានបញ្ចូលនូវទិដ្ឋភាពល្បែងរបាំចម្រុះច្រើនបែបច្រើនយ៉ាងដូច្នេះ គេច្រើនឃើញតែក្នុងសិល្បៈគំនូរបុរាណតែប៉ុណ្ណោះ។



រូបលេខ១២ សិល្បៈ ល្បែងរបាំ និងល្បែងប្រើរាងកាយផ្សេងៗគូរនៅព្រះវិហារវត្តកំពង់ត្រឡាចលើ

---

[6] អាំង ជូលាន, ២០០៥-២០០៦, ទំ. ៣៥-៣៧

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## អត្ថបទ៖ ប្រពៃណីទំនៀមទម្លាប់ដក់ជាប់លើគំនូរ (ភាគ២បញ្ចប់)

សព្វថ្ងៃល្បែងចំបាប់ដូចនៅក្នុងគំនូរខាងលើ ក៏ឃើញធ្លាប់ឃើញសម្តែងក្នុងសម័យបារាំងនៅមុខប្រាសាទអង្គរវត្ត(រូបលេខ១៣) ហើយបច្ចុប្បន្នអ្នកភូមិខ្លះចំណុះជើងវត្តតែងលេងជារឿយៗក្នុងវេលាមានបុណ្យទានដូចជា នៅវត្តដំរិល ខេត្តត្បូងឃ្មុំ (រូបលេខ១៤) និងនៅវត្តស៊ីធរ ខេត្តកណ្តាល តែងលេងចំបាប់ក្នុងថ្ងៃភ្ជុំធំ។ ចំណែកឯសិល្បៈប្រើពងកាយ(សៀក)ដទៃទៀត ឃើញមានបង្ហាត់បង្រៀននៅតាមសាលាសិល្បៈផងដែរ (រូបលេខ១៥)។ ទន្ទឹមនេះអ្វីជាមោទនភាពបំផុត គឺក្បាច់គុនល្បុក្កតោ ដែលជាក្បាច់គុនប្រពៃណីឃើញមានកស្តុតាងលើជញ្ជាំងប្រាសាទបុរាណ និងបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ តាំងពីឆ្នាំ២០២២។



*រូបលេខ១៣ចំបាប់សម្តែងមុខអង្គរវត្ត (រូប?)*



*រូបលេខ១៤ ចំបាប់សម្តែងនៅវត្តដំរិល ខេត្តត្បូងឃ្មុំ (រូបថត៖ TODAY)*



*រូបលេខ១៥ សិល្បៈសៀករបស់អង្គការហ្វាពន្លឺសិល្បៈ ខេត្តបាត់ដំបង*

សរុបសេចក្តីមក គំនូរតាមជញ្ជាំងវត្តអារាម មិនត្រឹមតែជាការគូរបង្ហាញរឿងរ៉ាវពាក់ព័ន្ធនឹងសាសនាប៉ុណ្ណោះទេ តែគឺជាបណ្ណសារដ៏សំខាន់ដែលបានបញ្ចូលនូវប្រពៃណីទំនៀមទម្លាប់ កិច្ចពិធី សិល្បៈតន្ត្រី និងល្បែងរបាំខ្មែរតាំងពីបុរាណ។ ការភ្ជាប់ទិដ្ឋភាពប្រតិបត្តិជាក់ស្តែងក្នុងសង្គមទៅក្នុងសិល្បៈគំនូរនេះ មិនត្រឹមតែឆ្លុះបញ្ចាំងពីកស្តុតាងដ៏មានតម្លៃនៃសម័យកាលនីមួយៗទេ តែបង្ហាញកាន់តែច្បាស់ពីតួនាទីវត្តអារាមជាឃ្លាំងចំណេះដឹង និងជាកន្លែងសិក្សាស្វែងយល់រៀនសូត្រ។ មិនតែប៉ុណ្ណោះសោត គំនូរទាំងនោះស្តែងពីទេពកោសល្យសិល្បករ ច្នៃបញ្ចូលនូវទេសភាពវប្បធម៌ទៅក្នុងជំនឿពុទ្ធប្រវត្តិ និងរឿងជាតក៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង


ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

២០១៧, *បញ្ជីសារពើភណ្ឌមរតកវប្បធម៌អរូបីកម្ពុជា*, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ភ្នំពេញ

ខៀវ ច័ន្ទ និង អ៊ឹម សុខរិទ្ធី

"កោរជុកនៅអង្គរវត្ត" ផ្សាយលើតំណ https://www.yosothor.org/publications/khmer-renaissance/chapter-two/kor-chuk-nov-angkor.html

ចាប ពិន

១៩៦០, *ព្រះរាជពិធីទ្វាទសមាស*, ភាគ៣, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

អាំង ជូលាន,

២០០៥-២០០៦, "ចំបាប់និងល្បែងប្រើកាយ", *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ*, Friends of Khmer Culture, ភ្នំពេញ, ទំ. ៣៥-៣៧

២០០៥-២០០៦, "កោរជុក", *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ*, Friends of Khmer Culture, ភ្នំពេញ, ទំ. ៤១-៤២


អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត